ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៥/១៤ - ស៊ុណូ ហ្គាមេន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេង ថុង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ស៊ុណូ ហ្គាមេន**

អាសយដ្ឋាន ៖ ភូមិព្រែកសំរោង ឃុំតាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១៦ ២៣៤ ២៣៦ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖

| | |
|---|---|
| ១- លោក គីម រតនា | រដ្ឋបាល |
| ២- លោក តាំង ម៉េង | តំណាងក្រុមហ៊ុន |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហភាពជាតិកម្ពុជាការពារកម្មករ**

- **សហជីពកម្ពុជា-អាស៊ានក្រុមហ៊ុន ស៊ុណូ ហ្គាមេន អ៊ិនដាស្រ្ទី ខូអិលធីឌី**

អាសយដ្ឋាន ៖ ផ្ទះលេខ២០៧ ផ្លូវលេខ០១៩Eo ក្រុម៣១ ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១៧ ៧២៨ ៤៧២ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

| | | |
|---|---|---|
| ១- | លោក សៀង រិទ្ធី | អគ្គលេខាធិការសហភាពជាតិកម្ពុជាការពារកម្មករ |
| ២- | លោក ផល សុវណ្ណារ៉ា | មន្ត្រីសហភាពជាតិកម្ពុជាការពារកម្មករ |
| ៣- | កញ្ញា ហ៊ុន ស្រីម៉ៅ | លេខាធិការសហជីពកម្ពុជា-អាស៊ានក្រុមហ៊ុន ស៊ីណូ ហ្គាមេន អ៊ិនដាសស្ទ្រី ខូអិលធីឌី |
| ៤- | កញ្ញា ប្រាក់ សុខរស់ | អនុប្រធានសហជីពកម្ពុជា-អាស៊ានក្រុមហ៊ុន ស៊ីណូ ហ្គាមេន អ៊ិនដាសស្ទ្រី ខូអិលធីឌី |
| ៥- | កញ្ញា កាំង ម៉ាន់នី | លេខាធិការសហជីពកម្ពុជា-អាស៊ានក្រុមហ៊ុន ស៊ីណូ ហ្គាមេន អ៊ិនដាសស្ទ្រី ខូអិលធីឌី |
| ៦- | កញ្ញា ឃឹម ណាវី | ប្រធានសហជីពកម្ពុជា-អាស៊ានក្រុមហ៊ុន ស៊ីណូ ហ្គាមេន អ៊ិនដាសស្ទ្រី ខូអិលធីឌី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- បងប្អូនកម្មករដែលបានចូលរួមក្នុងអំឡុងពេលធ្វើកូដកម្មចាប់ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ សូមឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗ។ ក្រុមហ៊ុនមិនឯកភាព។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ១៣០/១៤ កប/កណ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់សហភាពជាតិកម្ពុជាការពារកម្មករ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ ដដែល មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន ០៣ ចំណុច ដោយទទួលបានលទ្ធផលសះជាចំនួន ០២ ចំណុច និងមិនសះជាចំនួន ០១ ចំណុច ។ ចំណុចមិនសះជាចំនួន ០១ ចំណុច ដែលនៅសល់នេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ស៊ីណូ ហ្គាមេន លេខ ១៣០/១៤ កប/កណ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៤ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ០៨៖៣០ នាទីព្រឹក ក៏ប៉ុន្តែ តាមរយៈការស្នើសុំរបស់ភាគីនិយោជក សវនាការត្រូវបានពន្យារទៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ១៤៖០០ នាទីរសៀលវិញ ។ ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ១៤៖០០ នាទីរសៀល តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វែងរកនូវអង្គហេតុផ្សេងៗ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០១ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាឡើយ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទដែលនៅសល់ខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់នាយិកាក្រុមហ៊ុន ស៊ីណូ ហ្គាមេន ផ្ទេរសិទ្ធិជូនលោក គឹម រតនា ជារដ្ឋបាល ដើម្បីជួយដោះស្រាយវិវាទការងារ ។

២- លិខិតលេខ ១៦៧៤ កប/អក/វក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក អ្នកស្រី ខឹម វាសនា ស្តីពីការចុះបញ្ជិកាសហជីពកម្ពុជា-អាស៊ានក្រុមហ៊ុន ស៊ីណូ ហ្គាមេន អ៊ិនដាសស្ទ្រី ខូ អិលធីឌី ។

៣- ឯកសារជាភាសាបរទេស ។

THE ARBITRATION COUNCIL

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស៊ីណូ ហ្គាមេន លេខ ១៣០/១៤ កប/កណ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ស៊ីណូ ហ្គាមេន ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ ២០១៤។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០៧៣ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០៧៤ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ស៊ីណូ ហ្គាមេន ជាក្រុមហ៊ុន ដែលមានកម្មវត្ថុអាជីវកម្ម ក្នុងការកាត់ដេរសំលៀកបំពាក់។ នៅថ្ងៃសវនាការ ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុននេះ បានចាប់ផ្តើមដំណើរការអាជីវកម្ម អស់រយៈពេលជាង ០៨ ឆ្នាំ មកហើយ និងមានការផ្លាស់ប្តូរឈ្មោះជាច្រើនលើកច្រើនសារ ដែលឈ្មោះចុងក្រោយរបស់ក្រុមហ៊ុន គឺ ស៊ីណូ ហ្គាមេន។ បន្ថែមពីនេះ ក្រុមហ៊ុននេះ មានការផ្លាស់ប្តូរថៅកែថ្មី នៅក្នុងឆ្នាំ២០១២ ហើយសព្វថ្ងៃ ក្រុមហ៊ុនជួលកម្មករនិយោជិតសរុបប្រមាណជា ៧០០ នាក់។
- សហជីពកម្ពុជា-អាស៊ានក្រុមហ៊ុន ស៊ីណូ ហ្គាមេន អ៊ិនដាសស្ទ្រី ខូអិលធីឌី មិនទាន់មានវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីព ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅឡើយទេ។
- កម្មករនិយោជិតចំនួន ០៤ នាក់ នៃក្រុមហ៊ុន ស៊ីណូ ហ្គាមេន រួមមាន ៖ ១) កម្មការិនី ហ៊ុន ស្រីម៉ៅ ២) កម្មការិនី ប្រាក់ សុខរស់ ៣) កម្មការិនី កាំង ម៉ាន់នី និង ៤) កម្មការិនី ឃឹម ណាវី បានមកចូលរួមសវនាការអាជ្ញាកណ្តាល នាថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤។ ដោយសារតែមានភាពមិនច្បាស់លាស់ ទាក់ទងនឹងលិខិតផ្ទេរសិទ្ធិ ភាគីកម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា សម្រេចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល ពិចារណាចំពោះតែកម្មករនិយោជិតចំនួន ០៤ នាក់ ដែលមានវត្តមានក្នុងសវនាការនេះប៉ុណ្ណោះ។ ហេតុនេះ កម្មករនិយោជិតទាំង ០៤ នាក់ នៃក្រុមហ៊ុន ស៊ីណូ ហ្គាមេន ដែលមានវត្តមាន នៅថ្ងៃសវនាការ គឺជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។

THE ARBITRATION COUNCIL



148

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតដែលបានចូលរួម ក្នុងអំឡុងពេលធ្វើកូដកម្ម ចាប់ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០១៣ ទាមទារឱ្យនិយោជករក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗ**

- កម្មករនិយោជិតនៃក្រុមហ៊ុន ស៊ីណូ ហ្គាមេន បានចូលរួមធ្វើកូដកម្ម ចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដែលមានរយៈពេលសរុបចំនួន ០៥ ថ្ងៃ កន្លះ។ និយោជកបានកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ទាំងអស់ ចំនួន ០៦ ថ្ងៃ របស់កម្មករនិយោជិត ដែលបានចូលរួមកូដកម្ម ចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យភាគីនិយោជករក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ ដល់កម្មករនិយោជិតដែលជាកូដករ សម្រាប់អំឡុងពេលធ្វើកូដកម្ម ចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - កូដកម្ម ដែលធ្វើឡើងចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៣ គឺជាកូដកម្ម ដែលកើតឡើងទូទាំងប្រទេស។ ពោលគឺ មិនមែនមានតែកម្មករនិយោជិតនៃក្រុមហ៊ុន ស៊ីណូ ហ្គាមេន ដែលបានចូលរួមធ្វើកូដកម្មប៉ុណ្ណោះទេ។
  - បន្ទាប់ពីថ្ងៃកូដកម្ម កម្មករនិយោជិតនៃក្រុមហ៊ុន ស៊ីណូ ហ្គាមេន បានចូលធ្វើការវិញនៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ តាមកាលកំណត់ក្នុងប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលប្រកាសឱ្យកម្មករនិយោជិត ដែលបានធ្វើកូដកម្មទូទាំងប្រទេស ចូលធ្វើការជាធម្មតាវិញ ចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤។ ការដែលកម្មករនិយោជិតចូលធ្វើការវិញ តាមកាលកំណត់ ក្នុងប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺកម្មករនិយោជិតបានយល់យោគដល់ក្រុមហ៊ុន ព្រោះកម្មករនិយោជិតនៃរោងចក្រផ្សេងៗទៀត នៅតែបន្តធ្វើកូដកម្មនៅឡើយ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ នេះ ទោះបីជាមានប្រកាសពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក៏ដោយ។
  - និយោជកគួរយោគយល់ដល់កម្មករនិយោជិត និងគួរតែអនុវត្តដូចគ្នានឹងរោងចក្រផ្សេងៗ ដែលរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ដល់កម្មករនិយោជិត ដែលជាកូដករក្នុងអំឡុងពេលកូដកម្ម ចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។ រោងចក្រទាំងនោះ រួមមាន ៖
    - រោងចក្រ ហ្គាវីន រក្សាប្រាក់ឈ្នួល ដោយធ្វើការកាត់កងជាមួយការឈប់សម្រាកប្រចាំឆ្នាំ។
    - រោងចក្រ អ៊ី ហ្គាមេន រក្សាប្រាក់ឈ្នួលពាក់កណ្តាល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ទាំងអស់។
    - រោងចក្រ គីង សេង រក្សាប្រាក់រង្វាន់ធ្វើការទៀងទាត់ទាំងអស់ និងរក្សាប្រាក់ឈ្នួល ដោយធ្វើការកាត់កងជាមួយការឈប់សម្រាកប្រចាំឆ្នាំ។
    - រោងចក្រ ប្រេន្ត អ៊ីន រក្សាប្រាក់ឈ្នួលទាំងអស់។

- ការដែលនិយោជកកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់របស់កម្មករនិយោជិតទាំងអស់ សម្រាប់អំឡុងពេលកូដកម្ម គឺធ្វើឱ្យប៉ះពាល់អារម្មណ៍របស់កម្មករនិយោជិត ហើយកម្មករនិយោជិតមួយចំនួនបានលាឈប់ពីក្រុមហ៊ុន ដោយសារការកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់នេះ ។

- ភាគីកម្មករនិយោជិតបានបន្តថា កូដកម្មគឺធ្វើឡើងដោយការផ្អើលតាមគ្នា ដោយមិនបានធ្វើឡើងតាមការបោះឆ្នោតជាសម្ងាត់ ស្តីពីការសម្រេចធ្វើកូដកម្មនោះទេ ហើយក៏មិនមានការជូនដំណឹងមុនទៅនិយោជកដែរ អំពីការធ្វើកូដកម្មនេះ ។ ភាគីកម្មករនិយោជិត បានបញ្ជាក់បន្ថែមថា ក្នុងអំឡុងពេលកូដកម្មនេះ និយោជកមិនបានជួលកម្មករថ្មីមក ជំនួសកម្មករនិយោជិតដែលចូលរួមកូដកម្មនោះទេ ។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអាចផ្តល់ឱ្យតាមការទាមទាររបស់ភាគីកម្មករនិយោជិតនោះទេ ដោយហេតុថា ៖
  - យោងតាមច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ កិច្ចសន្យាការងារត្រូវបានព្យួរ ដូចនេះ កម្មករនិយោជិតមិនទទួលបានប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗទេ ពេលធ្វើកូដកម្ម ។
  - កម្មករនិយោជិតនៃក្រុមហ៊ុន ស៊ីណូ ហ្គាមេន ធ្វើកូដកម្មញឹកញាប់ ហើយមិនគោរពតាមនីតិវិធីកូដកម្មស្របច្បាប់នោះទេ ពោលគឺ មិនដោះស្រាយវិវាទដោយសន្តិវិធីឡើយ ។
  - ការដែលភាគីកម្មករនិយោជិតលើកឡើងថា កូដកម្មបានធ្វើឡើងទូទាំងប្រទេសនៅ ពេលរសៀលថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ គឺមិនត្រឹមត្រូវនោះទេ ។ កូដកម្មទូទាំងប្រទេស គឺធ្វើឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៣ ។ ការធ្វើកូដកម្ម ចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ គឺដោយសារកម្មករនិយោជិតមួយចំនួន ចង់បង្កើនប្រជាប្រិយភាពខ្លួន ក្នុងការបង្កើតសហជីព ។
  - នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ មានតែកម្មករនិយោជិតមួយចំនួនប៉ុណ្ណោះ ដែលចូលមកធ្វើការវិញ ។ រហូតមកដល់ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ ទើបកម្មករនិយោជិតទាំងអស់ ចូលធ្វើការគ្រប់គ្នា ហើយការដែលកម្មករនិយោជិតចូលធ្វើការវិញនេះ គឺដោយសារការប្រកាសរបស់រដ្ឋាភិបាល ។ ពោលគឺមិនមែនដោយសារកម្មករនិយោជិតយោគយល់ដល់និយោជក ដូចការលើកឡើងរបស់ភាគីកម្មករនិយោជិតនោះទេ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យភាគីនិយោជករក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ ដល់កម្មករនិយោជិតដែលជាកូដករ សម្រាប់អំឡុងពេលធ្វើកូដកម្ម ចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣**

កម្មករនិយោជិតចំនួន ០៤ នាក់ នៃក្រុមហ៊ុន ស៊ីណូ ហ្គាមេន រួមមាន ៖ ១) កម្មការិនី ហ៊ួន ស្រីម៉ៅ ២) កម្មការិនី ប្រាក់ សុខរស់ ៣) កម្មការិនី កាំង ម៉ាន់នី និង ៤) កម្មការិនី ឃឹម ណាវី ដែលបានមកចូលរួមសវនាការអាជ្ញាកណ្តាល នាថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ គឺជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាចំពោះតែកម្មករនិយោជិតចំនួន ០៤ នាក់ ដែលមានវត្តមានក្នុងសវនាការនេះប៉ុណ្ណោះ ។

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ ដល់កម្មករនិយោជិតដែលជាកូដករ សម្រាប់អំឡុងពេលធ្វើកូដកម្ម ចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដែរ ឬទេ?

មាត្រា ៣៣២ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីការងារចែងថា *"កិច្ចសន្យាការងារត្រូវព្យួរនៅពេលធ្វើកូដកម្ម ។ ក្នុងអំឡុងពេលនៃកូដកម្ម គាវកាលិកការងារមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រាក់បៀវត្សមិនត្រូវបានបើកឱ្យដែរ ។..."*

មាត្រា ៣៣៤ នៃច្បាប់ស្តីពីការងារចែងថា *"ក្នុងអំឡុងពេលធ្វើកូដកម្ម ត្រូវហាមឃាត់មិនឱ្យនិយោជកជ្រើសរើសកម្មករនិយោជិតផ្សេងមកជំនួសកូដករទាំងអស់... រាល់ការរំលោភលើវិធាននេះ តម្រូវឱ្យនិយោជកមានកាតព្វកិច្ច បើកប្រាក់បៀវត្សឱ្យកម្មករនិយោជិតដែលជាកូដករទាំងអស់ នៅក្នុងរយៈពេលធ្វើកូដកម្ម"*។

មាត្រា ៧២ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីការងារចែងថា *"ការព្យួរកិច្ចសន្យាការងារនាំឱ្យប៉ះពាល់ចំពោះតែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទបញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត..."* ។

នៅក្នុងសំណុំរឿង ២៧/១០-ហាត អ៊ិនធើប្រាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា *"ផ្អែកតាមខ្លឹមសារនៃមាត្រា ៣៣២ និងមាត្រា ៧២ (១) នៃច្បាប់ស្តីពីការងារ គឺនៅថ្ងៃ ឬខែណា ដែលកម្មករនិយោជិតធ្វើកូដកម្ម ទោះបីកូដកម្មត្រឹមត្រូវ តាមនីតិវិធីច្បាប់ ឬមិនត្រឹមត្រូវតាមនីតិវិធីច្បាប់ក៏ដោយ និយោជកមិនតម្រូវឱ្យផ្តល់ប្រាក់ឈ្នួល ឬប្រាក់រង្វាន់ដល់កម្មករនិយោជិតទេ ក្នុងអំឡុងពេលថ្ងៃណា ឬខែណា ដែលបានធ្វើកូដកម្មនោះ។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនជាប់កាតព្វកិច្ចត្រូវផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតដែលជាកូដករ ក្នុងអំឡុងពេលធ្វើកូដកម្មឡើយ ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៩/០៥-អូ សេ អង់ ហ្គាមិន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៣ )* ។

ទន្ទឹមនឹងនេះ ក្នុងសំណុំរឿង ១៧៨/១២-ដេខ្សូ (ខេមបូឌា) ហេតុផលចំណុចវិវាទទី១, ទី ២, និងទី ៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រា ៣៣២ កថាខណ្ឌទី១ និងមាត្រា ៣៣៤ នៃច្បាប់ស្តីពីការងារថា *" ក្នុងអំឡុងពេលធ្វើកូដកម្ម និយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់បៀវត្សដល់កម្មករនិយោជិតដែលជាកូដករនោះទេ ប៉ុន្តែក្នុងករណីដែលនិយោជកបានជ្រើសរើសកម្មករនិយោជិតថ្មីដើម្បីជំនួសកូដករ នោះនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់បៀវត្សដល់កម្មករនិយោជិត ដែលជាកូដករទាំងនោះ ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗផងដែរ ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា កូដកម្មគឺធ្វើឡើងដោយការផ្តើលតាមគ្នាដោយមិនបានធ្វើឡើងតាមការបោះឆ្នោតជាសម្ងាត់ស្តីពីការសម្រេចកូដកម្មនោះទេ ហើយក៏មិនមានការជូនដំណឹងមុនទៅនិយោជកដែរ អំពីការធ្វើកូដកម្មនេះ។ ភាគីកម្មករនិយោជិត បានបញ្ជាក់បន្ថែមថា ក្នុងអំឡុងពេលកូដកម្មនេះ និយោជកមិនបានជ្រើសរើសកម្មករនិយោជិតថ្មីមកជំនួសកូដករទាំងអស់នោះទេ។

សរុបមក យោងតាមមាត្រា ៣៣២ កថាខ័ណ្ឌទី១, មាត្រា៣៣៤, មាត្រា ៧២ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពី

ការងារ និងយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជក មិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ ដល់កម្មករនិយោជិតដែលចូលរួមធ្វើកូដកម្មទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជករក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ ដល់កម្មករនិយោជិត ចំនួន ០៤ នាក់ រួមមាន ៖ ១) កម្មការិនី ហ៊ុន ស្រីម៉ៅ ២) កម្មការិនី ប្រាក់ សុខរស់ ៣) កម្មការិនី កាំង ម៉ាន់នី និង ៤) កម្មការិនី ឃឹម ណាវី ដែលជាកូដករ សម្រាប់អំឡុងពេលធ្វើកូដកម្ម ចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## **សម្រេច និង បង្គាប់**

**ចំណុចវិវាទ ៖**

បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជករក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ ដល់កម្មករនិយោជិត ចំនួន ០៤ នាក់ រួមមាន ៖ ១) កម្មការិនី ហ៊ុន ស្រីម៉ៅ ២) កម្មការិនី ប្រាក់ សុខរស់ ៣) កម្មការិនី កាំង ម៉ាន់នី និង ៤) កម្មការិនី ឃឹម ណាវី ដែលជាកូដករ សម្រាប់អំឡុងពេលធ្វើកូដកម្ម ចាប់ពីពេលរសៀល ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **អាំង អេង ថុង**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL